**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/០៧ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤



Downloaded from http://www.khmerlaws.com

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៍ និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់ លក្ខណៈ ជីវសាស្ត្រសត្វព្រៃ ខេត្តកោះកុងក្នុងគោលបំណង÷

-ការពារ និង អភិរក្សរុក្ខជាតិព្រៃឈើ និង សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និង ប្រភេទជិតផុតពូជ

-ការពារច្រករបៀងសត្វជីវ៍ក្នុងភូមិភាគនិរតីនៃប្រទេសកម្ពុជា

-រៀបចំស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃ

-រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជម្រកសម្រាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ

-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍន៍ និង អភិរក្សជីជំរាល និង ជីវចំរុះ

-ការពារការហូរច្រោះ ទឹកជំនន់ ជីជាតិរបស់ដី រក្សានូវនិយតភាពនៃប្រភពទឹក និង គុណភាពទឹក

-ជំរុញការអប់រំ ផ្សព្វផ្សាយ និង អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ

-រួមចំណែកថែរក្សាកេរ្តិ៍ដំណែលវប្បធម៌ប្រវត្តិសាស្ត្រ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិក្នុងតំបន់។

**មាត្រា ២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការរៀបចំ និង គ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៍ និង មជ្ឈមណ្ឌលស្តារលទ្ធភាព ដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃ ខេត្តកោះកុងដោយសហការជាមួយក្រសួងពាក់ព័ន្ធ និង បង្កើតតំបន់អភិវឌ្ឍន៍កសិកម្មដែលផ្តល់ប្រយោជន៍ដល់សហគមន៍ មូលដ្ឋានប្រកបដោយនិរន្តរភាព។

**មាត្រា ៣.-**

ដំណើរការនៃការរៀបចំ និង ការគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៍ និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។



Downloaded from http://www.khmerlaws.com

## ជំពូកទី២
## វិសាលភាព

**មាត្រា ៤.-**

- តំបន់ព្រៃការពារ សម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៉ និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង មានផ្ទៃក្រឡា ១៤៤ ២៧៥ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា: A(334074, 1237322) B (333958, 1251538) C(340637, 1253405) D (338380, 1273232) E (326516, 1273260) F (320548, 1278873) G (314321, 1290020) H (309322, 1286590) I (291133, 1296529) J (280058, 1284999) K (283977, 1284463) L (287514, 1283233) M (289023, 1280539) N (297890, 1269927) O (306462, 1258808).

- ការកែប្រែផ្ទៃក្រឡាតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះការពារច្រករបៀងសត្វជីវ៉ និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុងនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## ការហាមឃាត់

**មាត្រា ៥.-**

សកម្មភាពគំរាមកំហែងដល់តំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៉ និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង ដូចខាងក្រោមត្រូវហាមឃាត់ដាច់ខាត:

-ការកែច្នៃផល អនុផលព្រៃឈើ ឬ ការបង្កើត និងដំណើរការមូលដ្ឋានឧស្សាហកម្ម សិប្បកម្មផ្សេងៗ និង ឡគ្រប់ប្រភេទ

-ការគាស់កកាយរករ៉ែ យកថ្មាំងសិលាដុតយកកំបោរ ឬ ធ្យូង ឬ គាស់កកាយដីច្រាប

-ការប្រមូលផល អនុផលព្រៃឈើ និងសកម្មភាពបរបាញ់ ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ព្រៃឈើ និង សត្វព្រៃគ្រប់ប្រភេទ

-ការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ និងការតាំងលំនៅដ្ឋានថ្មី ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។



Downloaded from http://www.khmerlaws.com

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិសាត់ និង អភិបាលខេត្តកំពង់ស្ពឺត្រូវ អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

Downloaded from http://www.khmerlaws.com




Downloaded from http://www.khmerlaws.com